**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ...០៣១.................សហវ.ភវព

ថ្ងៃ [illegible] ខែ បុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែមករា ឆ្នាំ២០២២

# សេចក្តីសម្រេច

## ស្តីពី

## ការកែសម្រួលសមាសភាពអនុគណៈកម្មការវាយតម្លៃអចលនទ្រព្យ សម្រាប់ពន្ធលើអចលនទ្រព្យ ខេត្តព្រះវិហារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ និងវិសោធនកម្មបន្តបន្ទាប់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៩/០២៦ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១០
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៤៩៣ សហវ.ប្រក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១០ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការប្រមូលពន្ធលើអចលនទ្រព្យ
- បានឃើញប្រកាសលេខ ៧៨៤ សហវ.ប្រក ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលសមាសភាពគណៈកម្មការវាយតម្លៃអចលនទ្រព្យ សម្រាប់ពន្ធលើអចលនទ្រព្យ
- យោងតាមការងារចាំបាច់ក្នុងការប្រមូលពន្ធលើអចលនទ្រព្យខេត្តព្រះវិហារ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92 Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855)23 890 666

## សម្រេច

**ប្រការ ១.-**

ត្រូវបានកែសម្រួលសមាសភាពអនុគណៈកម្មការវាយតម្លៃអចលនទ្រព្យ សម្រាប់ពន្ធលើអចលនទ្រព្យ ខេត្តព្រះវិហារ ដូចខាងក្រោម ÷

| | | | |
|---|---|---|---|
| ១. | ឯកឧត្តម **ប្រាក់ សុវណ្ណ** | អភិបាល នៃគណៈអភិបាលខេត្ត | ប្រធាន |
| ២. | លោក **ឃុត គឹមហ៊ាន** | អភិបាលរង នៃគណៈអភិបាលខេត្ត | អនុប្រធាន |
| ៣. | លោក **អាន សុទ្ធី** | ប្រធានសាខាពន្ធដារខេត្ត | អនុប្រធានប្រចាំការ |
| ៤. | លោក **សំ សារឿន** | ប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត | អនុប្រធាន |
| ៥. | លោក **ឃ៉ុត គឹមហឿង** | នាយករដ្ឋបាលសាលាខេត្ត | សមាជិក |
| ៦. | លោក **ពិន ទ្រីដា** | ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត | សមាជិក |
| ៧. | លោក **ម៉ុម សុផ្សាវ៉ា** | ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត | សមាជិក |
| ៨. | **លោកអភិបាល នៃគណៈអភិបាល គ្រប់ក្រុង/ស្រុក** | | សមាជិក |
| ៩. | លោក **សុខ សុគន្ធរ័ត្ន** | អនុប្រធានសាខាពន្ធដារខេត្ត | សមាជិក |
| ១០. | លោក **ម៉ុល បុរិន** | ប្រធានការិយាល័យសេវាអ្នកជាប់ពន្ធ នៃសាខាពន្ធដារខេត្ត | សមាជិក |
| ១១. | លោក **សុខ ប៊ុឡូ** | ប្រធានការិ.ទ្រព្យសម្បត្តិរដ្ឋ នៃមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត | សមាជិក |
| ១២. | **ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង/ស្រុក** | | សមាជិក |
| ១៣. | លោកស្រី **សំ សុដារ៉េត** | អនុប្រធានការិយាល័យសេវាអ្នកជាប់ពន្ធ នៃសាខាពន្ធដារខេត្ត | សមាជិក |
| ១៤. | **លោក លោកស្រី មេឃុំ ចៅសង្កាត់** | | សមាជិក |

**ប្រការ ២.-**

អនុគណៈកម្មការវាយតម្លៃអចលនទ្រព្យ សម្រាប់ពន្ធលើអចលនទ្រព្យ មានភារកិច្ច ដូចខាងក្រោម ÷

- រៀបចំបញ្ជីសរុបអចលនទ្រព្យ និងរៀបចំតម្លៃអចលនទ្រព្យតាមប្រភេទ និងតាមតំបន់ នៅតាមមូលដ្ឋានក្នុងដែនសមត្ថកិច្ចខេត្ត និងបញ្ជូនមកគណៈកម្មការវាយតម្លៃអចលនទ្រព្យ សម្រាប់ពន្ធលើអចលនទ្រព្យ
- ផ្សព្វផ្សាយ ណែនាំ និងអប់រំក្រុមការងារអចលនទ្រព្យឃុំ-សង្កាត់ ព្រមទាំងអ្នកជាប់ពន្ធ អំពីតម្លៃអចលនទ្រព្យ និងបទប្បញ្ញត្តិនានា ស្ដីពីការគ្រប់គ្រងប្រមូលពន្ធលើអចលនទ្រព្យ
- ផ្សព្វផ្សាយជាសាធារណៈ រួមទាំងបិទប្រកាសផ្សាយតម្លៃអចលនទ្រព្យ និងព័ត៌មានផ្សេងៗពាក់ព័ន្ធនឹងពន្ធលើអចលនទ្រព្យនៅតាមមូលដ្ឋានក្នុងដែនសមត្ថកិច្ចខេត្ត
- ធ្វើរបាយការណ៍ប្រចាំត្រីមាស និងប្រចាំឆ្នាំ ជូនគណៈកម្មការវាយតម្លៃអចលនទ្រព្យ សម្រាប់ពន្ធលើអចលនទ្រព្យ
- សម្របសម្រួល និងសហការជាមួយរដ្ឋបាលសារពើពន្ធ ក្នុងកិច្ចដំណើរការអនុវត្តការប្រមូលពន្ធលើអចលនទ្រព្យ
- តាមដាន ត្រួតពិនិត្យ រំលឹក ជំរុញការអនុវត្តភារកិច្ចរបស់ក្រុមការងារអចលនទ្រព្យឃុំ-សង្កាត់
- សមាជិកអនុគណៈកម្មការវាយតម្លៃអចលនទ្រព្យ សម្រាប់ពន្ធលើអចលនទ្រព្យ ត្រូវចូលរួមធ្វើការងារ និងប្រជុំតាមការអញ្ជើញរបស់ប្រធានអនុគណៈកម្មការ។

**ប្រការ ៣.-**

អនុគណៈកម្មការវាយតម្លៃអចលនទ្រព្យ សម្រាប់ពន្ធលើអចលនទ្រព្យ មានសិទ្ធិបង្កើតក្រុមការងារអចលនទ្រព្យឃុំ- សង្កាត់ ជាជំនួយការ។

ក្រុមការងារឃុំ- សង្កាត់ មានភារកិច្ច ដូចខាងក្រោម ÷

- ចូលរួមផ្តល់យោបល់ក្នុងការកំណត់តម្លៃអចលនទ្រព្យតាមប្រភេទ និងទីតាំងក្នុងដែនសមត្ថកិច្ច
- សហការផ្សព្វផ្សាយ ណែនាំ និងអប់រំអ្នកជាប់ពន្ធអំពីតម្លៃអចលនទ្រព្យ និងបទប្បញ្ញត្តិនានា ស្តីពីការគ្រប់គ្រងប្រមូលពន្ធលើអចលនទ្រព្យ
- សហការជាមួយរដ្ឋបាលសារពើពន្ធ ដើម្បីរៀបចំបញ្ជីលម្អិតអចលនទ្រព្យក្នុងដែនសមត្ថកិច្ច ហើយបញ្ជូនមកអនុគណៈកម្មការវាយតម្លៃអចលនទ្រព្យ សម្រាប់ពន្ធលើអចលនទ្រព្យ
- សហការផ្តល់ស្ថិតិ និងទិន្នន័យសម្រាប់ការចុះបញ្ជីអចលនទ្រព្យ ដល់រដ្ឋបាលសារពើពន្ធ
- សហការការងារដទៃទៀតតាមការស្នើសុំរបស់រដ្ឋបាលសារពើពន្ធ
- សមាជិកក្រុមការងារត្រូវចូលរួមធ្វើការងារ និងប្រជុំតាមសេចក្តីអញ្ជើញរបស់ប្រធានក្រុមការងារ
- ធ្វើរបាយការណ៍ប្រចាំត្រីមាស និងប្រចាំឆ្នាំ ជូនអនុគណៈកម្មការវាយតម្លៃអចលនទ្រព្យ សម្រាប់ពន្ធលើអចលនទ្រព្យ។

**ប្រការ ៤.-**

សេចក្តីសម្រេចណាដែលផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៥.-**

ឯកឧត្តម អស់លោក លោកស្រី ដែលជាសមាសភាពដូចមានចែងក្នុងប្រការ ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**
**រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**ប្រធានគណៈកម្មការវាយតម្លៃអចលនទ្រព្យ សម្រាប់ពន្ធលើអចលនទ្រព្យ**

**បណ្ឌិតសភាចារ្យ ជូ ចិន្តា**

**កន្លែងទទួល ÷**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង-ស្ថាប័ន
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលខេត្តព្រះវិហារ
  "ដើម្បីជូនជ្រាប និងសហការ"
- ដូចប្រការ ៥ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ